**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍ អភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍នៃសាលាភូមិន្ទរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ដែលសរសេរជាអក្សរកាត់ថា **ម.អ.ដ.ន.** ចំណុះឱ្យសាលាភូមិន្ទរដ្ឋបាល ក្នុងគោលបំណងរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អក្នុងវិស័យសាធារណៈ។

**មាត្រា២.-**

**ម.អ.ដ.ន.** មានបេសកកម្មសិក្សាស្រាវជ្រាវ ចងក្រង ផ្សព្វផ្សាយ និងចែករំលែកនូវចំណេះដឹង បទពិសោធ ឧត្តមានុវត្តន៍ និងនវានុវត្តន៍ លើផ្នែកអភិបាលកិច្ចក្នុងវិស័យសាធារណៈ។

**មាត្រា៣.-**

**ម.អ.ដ.ន.** បំពេញមុខងារដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវលើផ្នែកអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ នៅតាមក្រសួង ស្ថាប័ន គ្រឹះស្ថាន និងអង្គភាពសាធារណៈថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ចងក្រង បោះពុម្ព ផ្សព្វផ្សាយ និងរៀបចំវេទិកាចែករំលែកចំណេះដឹងនិងបទពិសោធអំពីអភិបាលកិច្ច ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ក្នុងវិស័យសាធារណៈ
- ផ្តល់ជំនួយបច្ចេកទេសនិងការពិគ្រោះយោបល់លើការកែលម្អអភិបាលកិច្ចដល់ក្រសួង ស្ថាប័ន
- ទទួលរៀបចំនិងអនុវត្តគម្រោងសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងបេសកកម្មរបស់មជ្ឈមណ្ឌល
- បំពេញមុខងារផ្សេងទៀត តាមការណែនាំរបស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាលាភូមិន្ទរដ្ឋបាល។

**មាត្រា៤.-**

ដើម្បីបំពេញបេសកកម្មនិងមុខងាររបស់ខ្លួន **ម.អ.ដ.ន.** ត្រូវបានផ្តល់សិទ្ធិនិងការទទួលខុសត្រូវដូចខាងក្រោម៖

- ទាក់ទងជាមួយក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រមូលនូវព័ត៌មាននិងទិន្នន័យដែលចាំបាច់សម្រាប់ការសិក្សាស្រាវជ្រាវក្នុងក្របខណ្ឌគតិយុត្តជាធរមាន
- សហការជាមួយស្ថាប័ន គ្រឹះស្ថានបណ្តុះបណ្តាលនិងសិក្សាស្រាវជ្រាវ អ្នកជំនាញជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍនានា
- ប្រើប្រាស់ព័ត៌មាននិងទិន្នន័យក្នុងក្របខណ្ឌនៃបេសកកម្មនិងមុខងាររបស់ខ្លួន អនុលោមតាមបទដ្ឋានគតិយុត្តជាធរមាននិងការកំណត់របស់ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាលាភូមិន្ទរដ្ឋបាល។

**មាត្រា៥.-**

**ម.អ.ដ.ន.** ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនតាមគម្រោង។

ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាលាភូមិន្ទរដ្ឋបាលកំណត់លក្ខណៈវិនិច្ឆ័យនិងប្រាក់ឧបត្ថម្ភសម្រាប់មុខតំណែងប្រធាននិងអនុប្រធាននៃ **ម.អ.ដ.ន.** ព្រមទាំងសម្រេចលើការតែងតាំងនិងបញ្ចប់ភារកិច្ចដោយផ្អែកលើសមិទ្ធិកម្មរបស់ **ម.អ.ដ.ន.**។

**មាត្រា៦.-**

កិច្ចដំណើរការរបស់ **ម.អ.ដ.ន.** ត្រូវអនុលោមតាមប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើសមិទ្ធិកម្មនិងគម្រោងសិក្សាស្រាវជ្រាវជាក់លាក់។

នាយកដ្ឋានស្រាវជ្រាវនិងទំនាក់ទំនងអន្តរជាតិនៃសាលាភូមិន្ទរដ្ឋបាលផ្តល់ការគាំទ្រនិងសម្របសម្រួលដល់ **ម.អ.ជ.ន**. ដើម្បីអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន។

**មាត្រា៧ ..**

គម្រោងសិក្សាស្រាវជ្រាវនីមួយៗត្រូវសម្រេចដោយក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាលាភូមិន្ទរដ្ឋបាល។

វិធាននិងនីតិវិធីនៃការរៀបចំនិងការអនុវត្តគម្រោងសិក្សាស្រាវជ្រាវត្រូវកំណត់ដោយក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃសាលាភូមិន្ទរដ្ឋបាល។

ថវិកាសម្រាប់ដំណើរការ **ម.អ.ជ.ន**. ស្ថិតក្នុងកញ្ចប់ថវិការបស់សាលាភូមិន្ទរដ្ឋបាល ដែលជាកញ្ចប់ថវិកាផ្ទាល់ដោយឡែកក្នុងថវិការបស់ក្រសួងមុខងារសាធារណៈ។

**មាត្រា៨ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៦ រោច ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ